

# តូតា នៅផ្ទះ

U U Story@ Dr. Zar Ni Win

Haru (AKZ)

Let's Read
The Asia Foundation



មានរឿងជាច្រើនដែលធ្វើឱ្យ តូតា សប្បាយចិត្ត។
តូតា ចូលចិត្តលេងបិទពួនជាមួយមិត្តភក្តិ និងត្រេកអរដែលត្រូវ
ចូលរៀនថ្នាក់មត្តេយ្យជាមួយពួកគេនៅឆ្នាំក្រោយ។



តូតា ចូលចិត្តពេលឪពុកមកលេងជាមួយនៅសួនច្បារ។
តូតា ក៏ចូលចិត្តនិយាយជាមួយម្ដាយនៅពេលគេហូបចំណីដែលខ្លួនចូលចិត្ត។



មីងរបស់ តូតា ជាអ្នកគ្រូពេទ្យ។ គាត់នៅឆ្ងាយពី តូតា ដើម្បីថែអ្នកជំងឺ។
ប៉ុន្តែមិនអីទេយ៉ាងណាក៏ តូតា បាននិយាយជាមួយគាត់តាមទូរស័ព្ទ ហើយពេលខ្លះគាត់ក៏ឆ្លៀតមកលេង តូតា ផងដែរ ។



ប៉ុន្តែថ្មីៗនេះអ្វីៗបានផ្លាស់ប្តូរ។
ឪពុកម្តាយរបស់គេគ្មានពេលជាមួយគេទៀតទេ ហើយមីងគេក៏ខានមកលេងគេទៀត។
តូតា មិនដឹងថាហេតុអ្វីនោះទេ។
មូលហេតុនេះធ្វើឱ្យ តូតា មិនសប្បាយចិត្តសោះ។ គេសង្ស័យថាពួកគាត់ប្រហែលឈប់ស្រឡាញ់រូបគេហើយ។



តូតា លែងបានអនុញ្ញាតឱ្យលេងជាមួយមិត្តភក្តិរបស់គេទៀតទេ។ ឪពុករបស់គេក៏មិនបានលេងជាមួយគេដូចមុន។ គេក៏មិនបានហូបចំណីដែលខ្លួនចូលចិត្តពេលនិយាយជាមួយម្តាយទៀតដែរ។ តូតា មិនចូលចិត្តបែបនេះទេ។



តូតា នៅតែអាចនិយាយជាមួយមីងតាមទូរស័ព្ទ។
គាត់បានប្រាប់ថា មានជំងឺម៉្យាងកើតឡើង ហើយឪពុកម្តាយគេ
កំពុងព្យាយាមឱ្យរូបគេមានសុវត្ថិភាព។ គាត់ក៏បានរំឭកដល់
តូតា ថាឪពុកម្តាយរបស់គេនៅតែស្រលាញ់រូបគេខ្លាំងណាស់
ហើយគេនឹងអាចធ្វើអ្វីជាច្រើនដែលខ្លួនចូលចិត្តបានវិញនាពេល
ឆាប់ៗនេះ។
រឿងនេះធ្វើឱ្យ តូតា សប្បាយចិត្តវិញ។



តូតា សម្រេចចិត្តស្វែងរកអ្វីដែលគេចូលចិត្តធ្វើ ក្រៅពីលេង
ជាមួយមិត្តភក្តិ។
គេអានសៀវភៅ និងគូររូបភាព។ គេថែមទាំងជួយការងារឪពុក
ម្តាយទៀតផង។
ការស្វែងរកវិធីថ្មីៗដើម្បីឱ្យខ្លួនឯងរីករាយ ធ្វើឱ្យ តូតា និងឪពុក
ម្តាយគេមានភាពរីករាយ។



ដោយឃើញ តូតា ផ្លាស់ប្តូរការលេងរបស់ខ្លួន ធ្វើឱ្យឪពុកម្តាយរបស់គេគិតអំពីការផ្លាស់ប្តូរដែលពួកគាត់អាចធ្វើបានផងដែរ។ ឪពុកគេចាប់ផ្តើមពាក់ម៉ាសនៅកន្លែងធ្វើការ និងលាងដៃគ្រប់ពេល។ ពេលត្រឡប់មកពីធ្វើការវិញគាត់ដូរខោអាវ និងលេងជាមួយ តូតា នៅក្នុងផ្ទះ។

រឿងនេះធ្វើឱ្យ តូតា និងឪពុកគេសប្បាយចិត្ត។



ម្ដាយរបស់គេចាប់ផ្ដើមទៅផ្សារឡើងវិញ ប៉ុន្តែគាត់ទៅ
តែមួយដងប៉ុណ្ណោះក្នុងមួយសប្ដាហ៍ ហើយគាត់ប្រុងប្រយ័ត្នរក្សា
គម្លាតរវាងខ្លួនគាត់ និងមនុស្សផ្សេងទៀតផងដែរ។
តូតា ហូបចំណីដែលគេចូលចិត្តនៅពេលនិយាយជាមួយម្ដាយ
របស់ខ្លួនម្ដងទៀត។
រឿងនេះធ្វើឱ្យ តូតា និងម្ដាយសប្បាយចិត្ត។



តូតា និងឪពុកម្ដាយរបស់គេសប្បាយចិត្តណាស់។ ជីវិតគឺខុសគ្នាពីអ្វីដែលធ្លាប់មានពីមុន ប៉ុន្តែពួកគេជួយការពារគ្នា និយាយជាមួយគ្នា និងស្រលាញ់គ្នាជានិច្ច។
ម៉ីងរបស់គេបាននិយាយថា តូតា ជាក្មេងល្អណាស់។



សំណួរ

១. តើឪពុកម្ដាយរបស់ តូតា ធ្លាប់ធ្វើអ្វីខ្លះជាមួយ តូតា?

២. ហេតុអ្វីបានជា តូតា មិនសប្បាយចិត្ត?

៣. តើមីងរបស់ តូតា បានពន្យល់អ្វីខ្លះដល់គេ?

៤. តើ តូតា បានធ្វើអ្វីខ្លះនៅផ្ទះ?

Third Story Project

The Asia Foundation

សៀវភៅនេះ ត្រូវបានបង្កើតឡើងក្រោមកិច្ចសហការរវាង គម្រោងរឿងទីបី និងអង្គការមូលនិធិអាស៊ី។

គម្រោងរឿងទីបី បង្កើត និងផលិតសៀវភៅរឿងសម្រាប់កុមារភូមា និងជាភាសាភូមាដើម្បីចែកចាយដោយឥតគិតថ្លៃដល់កុមារទូទាំងប្រទេសភូមា។ សាច់រឿងទាំងនេះ ត្រូវបាននិពន្ធ និងរចនារូបភាពឡើងដោយវិចិត្រករភូមា សម្រាប់អ្នកអានភូមា និងបង្ហាញពីបញ្ហាសន្តិភាព ការអត់ឱន នានាភាព យេនឌ័រ បរិស្ថាន និងសិទ្ធិកុមារ។

Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*သုတလေးအိမ်မှာနေမယ် (Thu Ta Stays Home)*, Author: U U Story@ Dr. Zar Ni Win. Illustrator: Haru (AKZ). Published by The Asia Foundation - Let’s Read, © The Asia Foundation - Let’s Read. Released under CC BY-NC 4.0.

This work is a modified version of the original story. © The Asia Foundation, 2020. Some rights reserved. Released under CC BY-NC 4.0.

For full terms of use and attribution,
http://creativecommons.org/licenses/by-nc/4.0/